# ការមិនគិតថ្លៃបន្ថែមរបស់ EBT – ក្រដាសសម្រាប់ដាក់លុយដោយផ្ទាល់

អ្នកអាចទទួលបានជំនួយលុយសុទ្ធ (cash aid) របស់អ្នកតាមរយៈ EBT ឬការដាក់លុយដោយផ្ទាល់ វាជាជម្រើសរបស់អ្នក! សូមប្រាប់បុគ្គលិកធ្វើការខោនធីរបស់អ្នកថាវិធីមួយណាដែលអ្នកចង់ទទួលជំនួយលុយសុទ្ធ (cash aid) របស់អ្នក។

អ្នកអាចប្តូរពី EBT ទៅការដាក់លុយដោយផ្ទាល់ឬពីការដាក់លុយដោយផ្ទាល់ទៅ EBT នៅពេលណាដែលអ្នកចង់។ សូមប្រាប់បុគ្គលិកធ្វើការខោនធីរបស់អ្នក ហើយពួកគេនឹងឲ្យការណែនាំទៅអ្នក។ ប្រសិនបើអ្នកមិនអាចប្រើកាត EBT ឬផ្នែកណានៃប្រព័ន្ធ EBT ទេ ដោយសារតែពិការភាព កម្រិតភាសា កង្វះមធ្យោបាយ ឬឧបសគ្គផ្សេងៗ សូមប្រាប់បុគ្គលិកធ្វើការខោនធីរបស់អ្នក ហើយពួកគេនឹងកំណត់ថាតើអ្នកមានសិទ្ធិសម្រាប់វិធីផ្សេងៗដើម្បីទទួលបានជំនួយលុយសុទ្ធ (cash aid) របស់អ្នក។

ប្រសិនបើអ្នកទទួលបានជំនួយលុយសុទ្ធ (cash aid) របស់អ្នកនៅថ្ងៃទីពីរឬទីបីនៃខែ អ្នកអាចមានលទ្ធភាពទទួលបានជំនួយលុយសុទ្ធ (cash aid) របស់អ្នកនៅថ្ងៃទីមួយនៃខែ ប្រសិនបើអ្នកមានការលំបាក។ សូមប្រាប់បុគ្គលិកធ្វើការខោនធីរបស់អ្នកថាហេតុអ្វីអ្នកត្រូវការទទួលបានជំនួយលុយសុទ្ធ (cash aid) របស់អ្នកនៅថ្ងៃទីមួយនៃខែ។ ប្រសិនបើអ្នកទទួលបានជំនួយលុយសុទ្ធ (cash aid) តាមការដាក់លុយដោយផ្ទាល់ ជាទូទៅអ្នកនឹងទទួលបានអត្ថប្រយោជន៍លុយសុទ្ធរបស់អ្នកនៅថ្ងៃទីមួយនៃខែ។

ប្រសិនបើអ្នកមានអត្ថប្រយោជន៍លុយសុទ្ធ EBT របស់អ្នកដកចេញពីគណនីរបស់អ្នកដោយសារតែការលួចតាមអេឡិចត្រូនិច ហើយអ្នកបានមានកាត EBT របស់អ្នកនៅក្នុងដៃរបស់អ្នកនៅពេលលួច សូមទូរស័ព្ទមកលេខ (877) 328-9677 ដើម្បីលុបចោលកាត EBT របស់អ្នកភ្លាមៗ ហើយទាក់ទងបុគ្គលិកធ្វើការខោនធីរបស់អ្នក។ អត្ថប្រយោជន៍អាចត្រូវបានជំនួស ប្រសិនបើតម្រូវការដាក់លាក់ត្រូវបានបំពេញ។

សូមចាំថា: អត្ថប្រយោជន៍ CalFresh ជាទូទៅត្រូវបានចេញឲ្យនៅលើកាត EBT របស់អ្នក ហើយអ្នកមិនគួរត្រូវបានគិតថ្លៃឈ្នួលនៅពេលធ្វើការទិញ CalFresh។

ខាងក្រោមគឺជាព័ត៌មានអំពី EBT និងការដាក់លុយដោយផ្ទាល់ដើម្បីជួយអ្នកជ្រើសរើស វិធីមួយណាដែលអ្នកចង់ទទួលបានជំនួយលុយសុទ្ធ (cash aid) របស់អ្នក។

## ប្រសិនបើអ្នកជ្រើសរើស EBT

អ្នកអាចទទួលបានលុយសុទ្ធដោយដកយកនៅឯ ATMs និងដោយការស្នើសុំលុយសុទ្ធមកវិញនៅពេលអ្នកបង់ថ្លៃការទិញ។

អ្នកអាចដកលុយសុទ្ធ **ដោយឥតគិតថ្លៃ** បួនដងក្នុងមួយខែនៅតាម ATMs ដែលមានសញ្ញា MoneyPass។ បន្ទាប់ការដកលើកទីបួនក្នុងមួយខែ ការដកនៅ ATM ម្តងៗ នឹងគិតលុយអ្នក 80 សេន។ ស្វែងរក MoneyPass ATMs ដែលឥតគិតថ្លៃបន្ថែមនៅតាម www.moneypass.com។ ការទទួលបានលុយសុទ្ធមកវិញនៅពេលអ្នកបង់ថ្លៃទំនិញ អាចដោយ**ឥតគិតថ្លៃ** សូមសួរអ្នកលក់ ។

ATMs ដែលគ្មានសញ្ញា MoneyPass អាចគិតលុយអ្នក $4 ឬច្រើនជាងនេះសម្រាប់ការដកប្រាក់ម្តងៗ។ ថ្លៃឈ្នួលទាំងនេះកើនយ៉ាងលឿន។

ប្រសិនបើគ្មាន MoneyPass ATM នៅជិតអ្នកទេ សូមរកមើល ATMs ផ្សេងទៀតដែលនឹងមិនគិតថ្លៃឈ្នួលអ្នក។ សូមចូលទៅ www.ebtproject.ca.gov/Library/Cash_Access.pdf ដើម្បីរកមើលបញ្ជីនៃ **ATMs ដែលមិនគិតថ្លៃបន្ថែម**។

ប្រសិនបើអ្នកបាត់កាត EBT របស់អ្នក ឬអ្នកណាម្នាក់លួចវា សូមទូរស័ព្ទមកសេវាអតិថិជនតាមរយៈលេខ (877) 328-9677 ភ្លាម។ អ្នកតំណាងសេវាអតិថិជននឹងលុបចោលកាត EBT របស់អ្នក ហើយជួយអ្នកឲ្យទទួលបានមួយថ្មីទៀត។ ប្រសិនបើអត្ថប្រយោជន៍ត្រូវបានយកដោយនរណាម្នាក់ផ្សេងទៀត មុនពេលអ្នកអាចទូរស័ព្ទមកសេវាអតិថិជន អត្ថប្រយោជន៍របស់អ្នកនឹងមិនត្រូវបានជំនួសទេ។

ប្រព័ន្ធ EBT កត់ទុកនូវទីកន្លែងដែលអ្នកប្រើកាតរបស់អ្នកដើម្បីដកលុយ និងបង់ថ្លៃទិញទំនិញ ប៉ុន្តែវាមិនកត់ទុកនូវអ្វីដែលអ្នកទិញទេ។ អ្នកអាចពិនិត្យប្រតិបត្តិការរបស់អ្នកដោយទូរស័ព្ទទៅលេខ (877) 328-9677 ឬមើលគណនី EBT របស់អ្នក សូមទៅអនឡាញទៅគេហទំព័រអតិថិជន EBT។ បង្កើតឈ្មោះអ្នកប្រើប្រាស់និងលេខសម្ងាត់នៅ www.ebt.ca.gov/caebtclient/clientcreate.recip។

## ប្រសិនបើអ្នកជ្រើសរើសការដាក់លុយដោយផ្ទាល់

អ្នកអាចទទួលបានលុយសុទ្ធដោយដកយកនៅឯ ATMs និងដោយការស្នើសុំលុយសុទ្ធមកវិញនៅពេលអ្នកបង់ថ្លៃការទិញ។

អ្នកអាចដល់លុយ **ដោយឥតគិតថ្លៃ** នៅឯ ATMs របស់ធនាគារអ្នក សូមសួរឬទៅធនាគាររបស់អ្នក។ ការទទួលបានលុយសុទ្ធមកវិញនៅពេលអ្នកបង់ថ្លៃទំនិញ អាចដោយ**ឥតគិតថ្លៃ** សូមសួរអ្នកលក់ ។

ATMs ដែលមិនមែនជារបស់ធនាគារអ្នកអាចគិតថ្លៃអ្នក $4 ឬច្រើនជាងនេះសម្រាប់ការដកម្តងៗបូកនឹងថ្លៃនានាដែលធនាគាររបស់អ្នកក៏អាចគិតថ្លៃផងដែរ។ ថ្លៃឈ្នួលទាំងនេះកើនយ៉ាងលឿន។

អ្នកអាចរកឃើញ ATMs របស់ធនាគារអ្នកដោយទូរស័ព្ទទៅលេខសេវាអតិថិជនធនាគារអ្នក ចូលមើលគេហទំព័ររបស់ពួកគេ ឬដោយទាញយកពាក្យសុំរបស់ពួកគេមកលើទូរស័ព្ទវៃឆ្លាតរបស់អ្នក។

ប្រសិនបើអ្នកបាត់កាត ATM របស់អ្នក ឬនរណាម្នាក់លួចវា សូមទូរស័ព្ទមកធនាគាររបស់អ្នក ភ្លាម។ ធនាគាររបស់អ្នកនឹងលុបចោលកាតរបស់អ្នក ហើយធ្វើកាតថ្មីឲ្យអ្នក។ ប្រសិនបើនរណាម្នាក់លួច និងប្រើកាតរបស់អ្នក អ្នកអាចបាត់បង់លុយដែលបានចំណាយខ្លះៗ ឬទាំងអស់។ ទាក់ទងធនាគាររបស់អ្នកដើម្បីស្វែងរកបន្ថែម។

ធនាគាររបស់អ្នកកត់ទុកនូវទីកន្លែងដែឡអ្នកប្រើកាត ATM របស់អ្នកដើម្បីដកលុយ និងបង់ថ្លៃទំនិញ។ អ្នកអាចពិនិត្យប្រតិបត្តិការរបស់អ្នកនៅលើរបាយការណ៍ប្រចាំខែរបស់អ្នក ដោយចូលទៅមើលគេហទំព័រធនាគាររបស់អ្នក ឬដោយទូរស័ព្ទទៅខ្សែសេវាអតិថិជនធនាគាររបស់អ្នក។

**សូមចងចាំថារក្សាទុកកាត ATM របស់អ្នក និងកាត EBT របស់អ្នកឲ្យមានសុវត្ថិភាព ហើយមិនត្រូវឲ្យលេខសំគាល់ខ្លួន (PIN) របស់អ្នកទៅនរណាម្នាក់។**